ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
30 / 08 / 2016
ម៉ោង (Time/Heure): 15:40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម យ៉ា សុខន, ជ.ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី 2-TCW-914

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលបានដាក់ជាឯកសារសម្ងាត់ នៅថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ សុំឱ្យទទួលយកខ្សែអាត់សម្លេងចំនួន ៤ ("ខ្សែអាត់សម្លេង") និង កំណត់ហេតុស្តាប់ចម្លើយចំនួន ១ ("ការស្តាប់ចម្លើយ") (រួមគ្នាហៅថា "សម្ភារៈ") ពាក់ព័ន្ធនឹងសាក្សី 2-TCW-914 ជាភ័ស្តុតាង ("សំណើសុំ") (ឯកសារ E432)។ សហព្រះរាជអាជ្ញាអន្តរជាតិកត់សម្គាល់ថា ការិយាល័យសហព្រះរាជអាជ្ញាបានរៀបចំការស្តាប់ចម្លើយនៅខែ មេសា ឆ្នាំ ២០០៨ តែលើកឡើងថា ឯកសារនេះបានបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យគ្រប់គ្រងសំណុំរឿង (CaseMap) ដោយការប្រកបឈ្មោះផ្សេងនៃឈ្មោះរបស់សាក្សី ហើយបន្ទាប់មកត្រូវបានមើលរំលងដោយអចេតនាក្នុងអំឡុងពេលពិនិត្យឯកសារពាក់ព័ន្ធ ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងបន្ថែមទៀតថា ដោយអនុលោមតាមការអនុវត្ត

ដែលអង្គជំនុំជម្រះបានបង្កើតឡើង ដើម្បីទទួលយកចម្លើយរបស់សាក្សីដែលបានជ្រើសរើសឱ្យមកផ្ដល់សក្ខីកម្ម សម្ភារៈទាំងនេះគួរត្រូវបានទទួលយកជាភស្តុតាង (ឯកសារ E432 កថាខណ្ឌ ២ យោងទៅឯកសារ E319/47/3)។ ភាគីផ្សេងទៀតមិនបានធ្វើការឆ្លើយតបទៅនឹងសំណើសុំនេះទេ។

២. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង នៅគ្រប់ដំណាក់កាលនៃនីតិវិធីទាំងអស់ អង្គជំនុំជម្រះអាចទទួលយកនូវភស្តុតាងទាំងឡាយណា ដែលអង្គជំនុំជម្រះយល់ឃើញថាមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត នៅពេលដែលភស្តុតាងនោះក៏បំពេញផងដែរនូវបទដ្ឋាន*ការបញ្ជាក់បឋម*នៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាព ដែលតម្រូវដោយវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះនឹងសម្រេចលើសំណើសុំឱ្យទទួលយកភស្តុតាងថ្មី ស្របតាមលក្ខណៈវិនិច្ឆ័យដូចមានចែងនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ក៏តម្រូវផងដែរថា ភាគីដែលស្នើសុំឱ្យទទួលយកភស្តុតាងថ្មីត្រូវបញ្ជាក់ពីមូលហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ ភាគីស្នើសុំត្រូវធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ភស្តុតាងដែលខ្លួនបានស្នើសុំដាក់ មិនអាចរកបាននៅមុនពេលចាប់ផ្ដើមជំនុំជម្រះ ឬ មិនអាចត្រូវបានរកឃើញ ទោះបីជាបានយកចិត្តទុកដាក់សមស្របហើយក៏ដោយ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងករណីមួយចំនួន អង្គជំនុំជម្រះសាលាដំបូងបានទទួលយកភស្តុតាងនានាដែលពុំបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យនេះឡើយ រួមទាំងក្នុងករណី ដែលភស្តុតាងពាក់ព័ន្ធយ៉ាងជិតស្និតជាមួយនឹងសម្ភារៈដែលមានរួចហើយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងក្នុងករណីដែលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យមានការវាយតម្លៃប្រភពទាំងនេះរួមគ្នា និងករណីដែលឯកសារដែលបានស្នើសុំដាក់នេះ គឺជាភស្តុតាងដោះបន្ទុក និងតម្រូវឱ្យមានការវាយតម្លៃ ដើម្បីជៀសវាងកំហុសក្នុងការស្វែងរកយុត្តិធម៌ (ឯកសារ E276/2 កថាខណ្ឌ ២ យោងទៅឯកសារ E190 និង E172/24/5/1, ឯកសារ E260 កថាខណ្ឌ ៥)។

៣. អង្គជំនុំជម្រះយល់ឃើញថា សម្ភារៈទាំងនេះ គឺជាចម្លើយរបស់សាក្សី 2-TCW-914 ដែលត្រូវបានកំណត់ឱ្យមកផ្ដល់សក្ខីកម្មនៅក្នុងសំណុំរឿងនេះ។ ការទទួលយកសម្ភារៈទាំងអស់នេះនឹងអនុញ្ញាតឱ្យមានការវាយតម្លៃពេញលេញទៅលើសក្ខីកម្មរបស់គាត់ និងគួរតែត្រូវបាន

ទទួលយកសម្រាប់ប្រយោជន៍យុត្តិធម៌។ អង្គជំនុំជម្រះកត់សម្គាល់ថា ខ្សែអាត់សម្លេងទីបួនក្នុងចំណោមខ្សែអាត់សម្លេងដែលបានបញ្ចូលទៅក្នុងឃ្លាំងផ្ទុកឯកសាររួម (T00185892-T00185892) ជាខ្សែអាត់ទទេ និងមិនមានសម្លេងពាក់ព័ន្ធនោះទេ ហើយហេតុនេះ មិនគួរទទួលយកជាភ័ស្តុតាងឡើយ។ អង្គជំនុំជម្រះជឿជាក់ថា ខ្សែអាត់សម្លេងផ្សេងទៀតមានភាពពាក់ព័ន្ធ និងទាក់ទងនឹងការស្តាប់ចម្លើយសាក្សី 2-TCW-914។ ការស្តាប់ចម្លើយ គឺជាប្រតិចារឹកនៃខ្សែអាត់សម្លេងទីបី (T00185891-T00185891) ដែលត្រូវបានបកប្រែជាភាសាអង់គ្លេស និងភាសាបារាំងរួចហើយ។ ខ្សែអាត់សម្លេងចំនួន ២ ដំបូងមិនត្រូវបានធ្វើប្រតិចារឹក ឬយកមកបកប្រែទេ។ ដោយយល់ឃើញថា សាក្សី 2-TCW-914 ត្រូវបានកំណត់ពេលឱ្យមកផ្តល់សក្ខីកម្មក្នុងពេលដ៏ខ្លីខាងមុខ អង្គជំនុំជម្រះសម្រេចទទួលយកសម្ភារៈទាំងនេះជាឯកសារភ័ស្តុតាង ទោះបីជាខ្សែអាត់សម្លេងទាំងនេះ មិនទាន់ត្រូវបានធ្វើប្រតិចារឹកឱ្យបានពេញលេញ ឬបានធ្វើការបកប្រែពីភាសាខ្មែរក៏ដោយ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះណែនាំឱ្យការិយាល័យសហព្រះរាជអាជ្ញាយកខ្សែអាត់សម្លេងចំនួន ២ ដំបូងមករៀបចំធ្វើប្រតិចារឹក និងបកប្រែឱ្យបានចប់សព្វគ្រប់ ដោយចាត់ទុកជាការប្រញាប់។

៤. ដោយអនុលោមទៅតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះសម្រេចតាមសំណើសុំឱ្យទទួលយកសម្ភារៈទាំងនេះ។ អង្គជំនុំជម្រះដាក់លេខសំគាល់ឯកសារ E3/10650R ចំពោះខ្សែអាត់សម្លេង ចំនួន ៣ ដំបូង និង ដាក់លេខសំគាល់ឯកសារ E3/10651 ចំពោះកំណត់ហេតុស្តាប់ចម្លើយ។

៥. អនុស្សរណៈនេះជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងឯកសារ E432។